**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**អគ្គនាយកដ្ឋានយោធសេវា**

**នាយកដ្ឋានព័ត៌មាន**

លេខ:...................

# សេចក្តីប្រកាសព័ត៌មាន

ឆ្លើយតបតាមការអញ្ជើញរបស់រដ្ឋមន្ត្រីការពារជាតិកាណាដា **សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិកម្ពុជា** នឹងដឹកនាំគណៈប្រតិភូក្រសួងការពារជាតិកម្ពុជា ទៅធ្វើទស្សនៈកិច្ចជាផ្លូវការ និងចូលរួមក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការពារជាតិស្តីពីការរក្សាសន្តិភាពក្នុងក្របខណ្ឌអង្គការសហប្រជាជាតិនៅទីក្រុង វែនគូវឺ ប្រទេសកាណាដា ចាប់ពីថ្ងៃទី ១២ ដល់ថ្ងៃទី ១៨ ខែវិច្ឆកា ឆ្នាំ ២០១៧ ។

គោលបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីវាយតំលៃការប្តេជ្ញាចិត្តនាពេលកន្លងមក ក្នុងប្រតិបត្តិការរក្សាសន្តិភាព និងបន្តជំរុញអោយមានការប្តេជ្ញាចិត្តថ្មីៗទៀត។ លើកកំពស់កំណែទំរង់ប្រតិបត្តិការរក្សាសន្តិភាពតាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់ រដ្ឋសមាជិក និងអង្គការសហប្រជាជាតិដើម្បីកែលំអរសមត្ថភាពក្នុងការធ្វើផែនការ និងការអនុវត្តការងារអោយកាន់តែប្រសើរ ។ ជំរុញអោយមានដំណោះស្រាយប្រកបដោយហេតុផល និង ការច្នៃប្រឌិត ដើម្បីធ្វើអោយប្រតិបត្តិការក្សសន្តិភាពកាន់តែមានប្រសិទ្ធភាព ។ កិច្ចប្រជុំនេះ ក៏មានគោលបំណង កែលំអរប្រសិទ្ធភាព ការងារតាមរយៈការ បង្កើនការចូលរួមរបស់ស្ត្រីក្នុងប្រតិបត្តិការរក្សាសន្តិភាព ដើម្បីធានាថា ស្ត្រីត្រូវបាន ផ្តល់សិទ្ធអំណាច និងទស្សនវិស័យយេនឌ័រត្រូវបានបញ្ចូលក្នុងទិដ្ឋភាពទាំងអស់នៃប្រតិបត្តិការរក្សាសន្តិភាព ។ ហើយកិច្ចប្រជុំនេះទៀត នឹងបញ្ជាក់ ពីការតាំងចិត្តលើវិស័យរក្សាសន្តិភាពតាមរយៈការប្រកាស បញ្ចូលកំលាំងត្រៀមបំរុង និង ការបង្កើនការចល័តអោយបានរហ័ស ។

ក្នុងដំណើរបំពេញទស្សនកិច្ចនេះ**សម្តេចពិជ័យសេនា ទៀ បាញ់** នឹងជួបពិភាក្សាការងារទ្វេភាគីជាមួយសមភាគីកាណាដានិងអគ្គលេខាធិការរង អ ស ប ទទួលបន្ទុកផ្នែករក្សាសន្តិភាពផងដែរ ។

**ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១៧**

នាយកដ្ឋានព័ត៌មាន